**ជូនចំពោះលោកនាយក/លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូ និងសហការីជាទីគោរព!**

**តាមរយៈ UNGEI និងយុទ្ធនាការសាកលសម្រាប់ការអប់រំ-សប្តាហ៍សកម្មភាពសាកលឆ្នាំ២០១១: មេរៀនស្តីពីរឿងធំ (Big Story Lesson): "វាជាសិទ្ធិ ។ ធ្វើវាឱ្យត្រឹមត្រូវ! ឥលូវសូមអនុវត្តការអប់រំក្មេងស្រី និងស្ត្រី!"**

---

កម្មវិធីផ្តួចផ្តើមការអប់រំក្មេងស្រីរបស់អង្គការសហប្រជាជាតិក្នុងតំបន់អាស៊ីបូពាប៉ាស៊ីហ្វិក(EAP UNGEI) កំពុងធ្វើការជាមួយយុទ្ធនាការសាកលសម្រាប់ការអប់រំ ហើយសូមគោរពអញ្ជើញសាលារៀនរបស់លោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូចូលរួមក្នុង**មេរៀនស្តីពីរឿងធំ (Big Story Lesson) ដែលនឹងប្រព្រឹត្តទៅក្នុងចន្លោះថ្ងៃទី០២ និងទី០៨ ខែឧសភា ឆ្នាំ២០១១** ។ កុមារ និងមនុស្សពេញវ័យរាប់លាននាក់មកពីប្រទេសជាង១០០នៅជុំវិញពិភពលោកនឹងចូលរួមក្នុងមេរៀនធំ ដើម្បីស្តាប់រឿងរ៉ាវរំភើបអំពីស្ត្រី និងកុមារីដែលគួរឱ្យសរសើរ ។ ស្ត្រី និងកុមារីទាំងនោះជាអ្នកបង្កើតនូវរឿងរ៉ាវរំភើបនានា តាមរយៈការអប់រំ ទោះបីជាពួកគេមួយចំនួនប្រឈមនឹងឧបសគ្គយ៉ាងណាក៏ដោយ ។ យើងខ្ញុំសង្ឃឹមថា សាលារៀនរបស់លោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូអាចចូលរួមក្នុងមេរៀនដ៏សំខាន់នេះ ហើយមេរៀននេះនឹងអប់រំ ព្រមទាំងផ្តល់ភាពកំសាន្តដល់អ្នកសិក្សាផងដែរ ។

**មេរៀនស្តីពីរឿងធំ** និយាយពីសារៈសំខាន់នៃការអប់រំរបស់ស្ត្រី និងក្មេងស្រី ។ ស្ត្រី និងកុមារីជាច្រើនមិនចេះសរសេរអក្សរ ឬអាន ពីព្រោះពួកគេមិនដែលចូលរៀន ។ ពួកគេមួយចំនួនបានចូលរៀន ប៉ុន្តែ បន្ទាប់មកក៏បោះបង់ការសិក្សា ពីព្រោះមិនមានថវិកាគ្រប់គ្រាន់សម្រាប់ចូលរៀន ។ ថ្នាក់ដឹកនាំ នៃរដ្ឋភាគីបានសន្យាថាពួកគេនឹងបង្កើតលក្ខខណ្ឌដែលបង្កឱកាសឱ្យស្ត្រី និងកុមារីទទួលបានការអប់រំ ហើយយើងខ្ញុំសង្ឃឹមថា ថ្នាក់ដឹកនាំទាំងនោះនឹងប្រតិបត្តិតាមការសន្យាក្នុងឆ្នាំ២០១១ ។

លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សមកពីសាលារៀនរបស់លោកនាយក លោកស្រីនាយិកានឹងមានឱកាសចូលរួមជាមួយមនុស្សរាប់លាននាក់ទៀត និងជាផ្នែកមួយនៃព្រឹត្តិការណ៍សាកលដ៏រំភើបនេះ ។ បទពិសោធន៍ស្តីពីកិច្ចតែងការនឹងត្រូវចែករំលែកជាមួយដៃគូរបស់ UNGEI ទូទាំងតំបន់ ជាពិសេសតាមរយៈសកម្មភាពគំនូរនៅចុងបញ្ចប់មេរៀន ។ ពេលចប់មេរៀន យើងខ្ញុំសូមឱ្យលោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូ

ចុះឈ្មោះចូលរួមតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីឱ្យសាលារៀនរបស់លោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូអាចចូលរួមជាមួយសាលារៀនរាប់ពាន់ទៀតជុំវិញពិភពលោក ។

យើងខ្ញុំបានរៀបចំឯកសារមួយចំនួនដើម្បីជួយលោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូចូលរួមក្នុង **មេរៀនស្ដីពីរឿងធំ** ។

- កិច្ចតែងការមេរៀនស្ដីពីរឿងធំ
- ការណែនាំស្ដីពីសកម្មភាពគំនូរ

យើងខ្ញុំសង្ឃឹមថា លោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូនឹងគិតពិចារណាចូលរួមក្នុងសកម្មភាពរំភើបនេះ សំដៅផ្ដល់ឱកាសដល់កុមារី និងស្ត្រីទាំងអស់ទទួលបានការអប់រំ ។

សូមលោកនាយក លោកស្រីនាយិកា លោកគ្រូ អ្នកគ្រូទទួលយកនូវការគោរពរាប់អានអំពីយើងខ្ញុំ ។

UNGEI United Nations Girls' Education Initiative | GLOBAL CAMPAIGN FOR EDUCATION www.campaignforeducation.org

## សប្ដាហ៍សកម្មភាពសាកលឆ្នាំ២០១១: កិច្ចតែងការមេរៀន "រឿងធំ" (BIG STORY LESSON PLAN)

## វាជាសិទ្ធិសម្រាប់កុមារី និងស្ត្រី ក្នុងការធានាថាពួកគេមានសិទ្ធិក្នុងការទទួលបានការអប់រំ

---

**វត្ថុបំណង:**

១. ពិភាក្សាអង្គហេតុដែលថាកុមារ និងមនុស្សពេញវ័យរាប់លាននាក់មិនដែលមានឱកាសទៅរៀន ហើយអ្នកទាំងនោះភាគច្រើនជាស្ត្រី និងកុមារី ។

២. លើកកម្ពស់ការយល់ដឹង និងលើកទឹកចិត្តសិស្សឱ្យក្រឡេកមើលពិភពលោកតាមរយៈទស្សនវិស័យយេនឌ័រ ។

៣. ពិភាក្សាអំពីការសន្យារបស់ថ្នាក់ដឹកនាំនៅតាមប្រទេសនានាក្នុងពិភពលោក និងពិភាក្សាលើអង្គហេតុដែលថាពួកគេមិនគោរពតាមការសន្យារបស់ខ្លួន ។

៤. បង្ហាញពីរបៀបដែលសិស្សអាចចូលរួមផ្សព្វផ្សាយដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាសាកល ។

**បន្ទាប់ពីបានចូលរួមក្នុងយុទ្ធនាការផ្សព្វផ្សាយ អ្នកចូលរួមទាំងអស់នឹង :**

- យល់ពីផលប្រយោជន៍ដែលអាចទទួលបានពីការអប់រំកុមារី ។
- យល់នូវភាពខុសប្លែកគ្នានៃរបៀបរស់នៅរបស់កុមារនៅតាមតំបន់ផ្សេងៗក្នុងពិភពលោក ។
- យល់ពីកត្តាដែលរួមចំណែកក្នុងការរក្សាក្មេងស្រីបន្តការសិក្សារបស់ខ្លួន និង ស្វែងយល់ពី ឧបសគ្គដែលរារាំងពួកគេក្នុងការទទួលបានការ អប់រំ ។

**<u>វគ្គ "ក":</u>**

**ផ្នែក "ក": សេចក្ដីផ្ដើម (រយៈពេល៥នាទី)**

គ្រូពន្យល់ថាកុមារនៅតាមប្រទេសនានាជុំវិញពិភពលោកបានចូលរួមជាមួយនឹងស្ត្រីល្បីៗមួយចំនួននៅក្នុងពិភពលោកក្នុងការផ្សព្វផ្សាយពីរឿងរ៉ាវ ផ្សេងៗពាក់ពន្ធ័នឹងសារៈសំខាន់នៃការអប់រំជា ពិសេសការអប់រំសម្រាប់កុមារី និងក្មេងស្រី និងក្នុងភាពសាមគ្គីជាធ្លុងមួយក្នុងការជួយដល់ ស្ត្រី និង កុមារីរាប់លាននាក់ដែលមិនបានទទួលការអប់រំ ។ គ្រូសួរទៅកាន់សិស្សទាំងអស់ អំពីចំនួនកុមារ និងមនុស្សចាស់ដែលនៅក្រៅសាលារៀន រឺប្រព័ន្ធអប់រំ ហើយក្នុងនោះតើមានកុមារី និងស្ត្រីចំនួនប៉ុន្មាននាក់ ។គ្រូអាចចែករំលែកតួលេខពិតប្រាកដជាមូលដ្ឋានមួយចំនួន:

- មានកុមារចំនួន៧២លាននាក់នៅជុំវិញពិភពលោកនៅក្រៅសាលារៀន ។
- ក្នុងចំណោមចំនួន៧២លាននាក់នេះ មានកុមារីចំនួន៥៤ភាគរយ (ប្រហែល៣៩លាននាក់) និង
- ២/៣នៃអនក្ខរជនដែលជាមនុស្សពេញវ័យជាស្ត្រី ។

កុមារីដែលមិនមានការអប់រំទំនងជានឹង:

- ឆាប់រៀបការ
- មានកូនខ្វះអាហាររូបត្ថម្ភ និងកូនស្លាប់ដោយសារជម្ងឺ
- ក្រីក្រ

គ្រូសួរសិស្សថាតើពួកគេមានស្គាល់ស្ត្រី ឬកុមារីណាម្នាក់ដែលបានធ្វើអ្វីមួយគួរឱ្យកត់សម្គាល់ដែរឬទេ ។ តើស្ត្រីរូបនេះទៅរៀនដែរឬទេ?

## ផ្នែក "ខ"- តួនាទីយេនឌ័រ និងការអប់រំ

គ្រូសួរសិស្សថាតើពួកគេអាចប្រាប់ពីរឿងរ៉ាវដែលបង្ករជាឧបសគ្គចំពោះវិសមភាពយេនឌ័រក្នុងវិស័យអប់រំរឺទេ?

គ្រូសួរអំពីសារៈសំខាន់នៃឱកាសទទួលបានការអប់រំសម្រាប់ស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ (*សម្រាប់ថ្នាក់កម្រិតខ្ពស់ សូមពិភាក្សាអំពីអនុសញ្ញាស្តីពីសិទ្ធិកុមារ*) ។ ការសង្ខេប:

- អនុសញ្ញាស្តីពីសិទ្ធិកុមារបានអនុម័តនៅឆ្នាំ១៩៨៩ ហើយវាជាលិខិតតុបករណ៍អន្តរជាតិផ្នែកច្បាប់ទីមួយដែលត្រូវប្រតិបត្តិតាម និងដែលបានបញ្ចូលពេញលេញនូវបញ្ញត្តិស្តីពីសិទ្ធិមនុស្ស ។

- វាបរិយាយលំអិតអំពីមូលដ្ឋានសិទ្ធិមនុស្ស ដែលកុមាររស់នៅកន្លែងណាក៏ដោយមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការអប់រំ ដោយមិនគិតពីឋានៈ សាសនា ពូជសាសន៍របស់ពួកគេឡើយ។ សិទ្ធិទាំងនេះរួមមានៈ សិទ្ធិរស់រានមានជីវិត; សិទ្ធិទទួលបានការរីកលូតលាស់ ពេញលេញ; សិទ្ធិទទួលបានកិច្ចគាំពារទល់នឹងឥទ្ធិពល ការរំលោភបំពាន និងការជិះជាន់ ដែលអាចបំផ្លិចបំផ្លាញ; និងសិទ្ធិចូលរួមចំណែកយ៉ាងពេញលេញក្នុងជីវភាព វប្បធម៌ និងសង្គម ។ អនសញ្ញាស្ដីពីសិទ្ធិកុមារមានគោលការណ៍សំខាន់៧៨ៈ ភាពមិនរើសអើង; ការលះបង់ចំពោះផលប្រយោជន៍របស់ កុមារ; សិទ្ធិរស់នៅ សិទ្ធិដើម្បីមានជីវិត និងសិទ្ធិទទួលបានការរីកលូតលាស់; និងការគោរពចំពោះទស្សនៈ ឬមតិយោបល់របស់កុមារ ។
- អនុសញ្ញាស្ដីពីសិទ្ធិកុមារជិតទទួលបានការទទួលយកជាសាកលហើយ ដោយឥលូវនេះមានប្រទេសចំនួន១៩៤ បានធ្វើសច្ចាប័នលើអនុសញ្ញានេះ ។
- ដោយយល់ស្របអនុវត្តកាតព្វកិច្ចចែងក្នុងអនុសញ្ញាស្ដីពីសិទ្ធិកុមារ (តាមរយៈធ្វើសច្ចាប័ន ឬដោយអនុលោមតាមអនុសញ្ញា) រដ្ឋាភិបាលតាមប្រទេសនានាបានប្ដេជ្ញាចិត្តការពារ និងធានាឱ្យមាននូវសិទ្ធិកុមារ ហើយរដ្ឋាភិបាលទាំងនោះទទួលខុសត្រូវចំពោះការប្ដេជ្ញាចិត្តរបស់ខ្លួន នៅមុខសហគមន៍អន្តរជាតិ ។

គ្រូចែករំលែកចំណេះដឹងខ្លះៗ ហើយពិភាក្សាអំពីភូមិសាស្ត្រ វប្បធម៌ផ្សេងៗ និងស្ថានភាពរស់នៅរបស់កុមារក្នុងប្រទេសអភិវឌ្ឍន៍តិចតួច ។

គ្រូសួរសិស្សអំពីអ្វីដែលពួកគេគិតអាចអនុវត្តដើម្បីលើកកម្ពស់ការទទួលបានឱកាសស្មើគ្នាៗ រវាងបុរស និងស្ត្រីនៅក្នុងការអប់រំ ។

គ្រូឱ្យសិស្សប្រាប់ឈ្មោះការងារមួយចំនួនដែលពួកគេដឹង និងសួរពួកគេថាតើការងារទាំងនេះជាទូទៅធ្វើឡើងដោយបុរស និង/ឬស្ត្រី ។

គ្រូសួរសិស្សថាតើការងារអ្វីខ្លះដែលតម្រូវឱ្យពួកគេធ្វើនៅផ្ទះ ។ តើមានការងារមួយចំនួនដែលជាទូទៅធ្វើឡើងដោយបុរស/ស្ត្រីដែរឬទេ? តើការបែងចែកការងារស្មើភាពគ្នាដែរឬទេ?
គ្រូសួរសិស្សថាតើពួកគេមានអារម្មណ៍ដូចម្តេច ប្រសិនបើឪពុកម្តាយប្រាប់ថាពួកគេមិនអាចទៅរៀនបានទេ ពីព្រោះមានការងារច្រើនត្រូវធ្វើនៅផ្ទះ ។

គ្រូសួរសិស្សថាតើមូលហេតុអ្វីបានជាការសិក្សាមានសារៈសំខាន់ និងមូលហេតុដែលកុមារមួយចំនួន ជាពិសេសកុមារីមិនទៅរៀន ។

ចម្លើយខ្លះៗ រួមមាន:

- *កុមារមួយចំនួនរស់នៅក្នុងតំបន់ជម្លោះ ឬទទួលរងផលប៉ះពាល់ពីគ្រោះមហន្តរាយធម្មជាតិ ។*
- *នៅក្នុងវប្បធម៌មួយចំនួន គេមិនផ្តល់អាទិភាពដល់កុមារីទេ ពេលមូលនិធិអប់រំមានការកំណត់ ។*
- *កុមារីត្រូវបង្ខំឱ្យឈប់រៀន ហើយរៀបការទាំងវ័យក្មេង ដើម្បីឱ្យពួកគេមានពេលវេលាធ្វើការងារផ្ទះ ។*
- *កុមារមួយចំនួនរស់នៅឆ្ងាយពីសាលារៀន ហើយការដែលទៅរៀនអាចបង្កឱ្យមាននូវគ្រោះថ្នាក់ ។ ដូច្នេះពួកគេត្រូវនៅផ្ទះ ។ ជាពិសេសកុមារីជាគោលដៅនៃការបៀតបៀន និងអំពើហិង្សា ។*
- *ភាពក្រីក្រ: កុមារមួយចំនួនត្រូវបង្ខំឱ្យធ្វើការរកប្រាក់ចំណូលសម្រាប់គ្រួសារ ។*
- *ពួកគេមិនមានលុយទិញសៀវភៅ និងឯកសណ្ឋានសិស្ស ។*
- *ពួកគេមិនមានលុយបង់ថ្លៃសាលា ។*
- *មិនមានសាលារៀនគ្រប់គ្រាន់ ។ និង*
- *មិនមានគ្រូគ្រប់គ្រាន់ ។*

**ផ្នែក "គ"-តើអាចធ្វើអ្វីបានខ្លះចំពោះបញ្ហានេះ? (រយៈពេល១០នាទី)**

គ្រូឱ្យសិស្សពិចារណាពីមូលហេតុថាតើហេតុអ្វីការអប់រំដល់ក្មេងស្រីមានសារៈសំខាន់ :
។ អាចមានចម្លើយដូចខាង ក្រោម:

- *បង្កើនការគាំទ្ររបស់រដ្ឋាភិបាលដល់ការអប់រំក្មេងស្រីក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។*

- *ផ្តល់បរិក្ខា ឬកន្លែងអនាម័យដល់ក្មេងស្រីដើម្បីឱ្យពួកគេការពារសិទ្ធិនៃជីវភាពឯកជនរបស់ពួកគេ ។*
- *លុបបំបាត់ផ្នត់គំនិតដែលទំនងធ្វើឱ្យកុមារីតូចទាបជាងគេ ។*
- *លុបបំបាត់ថ្លៃសាលា និងការចំណាយបង្កប់ផ្សេងៗដែលទាក់ទងនឹងការអប់រំ និង*
- *លើកទឹកចិត្តកុមារា និងបុរសឱ្យធ្វើជាអ្នកគស្ស័មតិលើការអប់រំស្ត្រី និងកុមារី ។*

គ្រូសួរសិស្សទាំងអស់នូវសំណួរខាងក្រោម ។ ប្រសិនបើមានអ្នកនយោបាយ អ្នកអាចនឹងអំពាវនាវពួកគេឱ្យឆ្លើយសំណួរមួយចំនួនខាងក្រោម:

- *តើមានកុមារប៉ុន្មាននាក់ក្នុងពិភពលោកនៅក្រៅសាលារៀន?*
- *តើក្រុមណាបាត់បង់ឱកាសជាងគេទាក់ទងនឹងការអប់រំ?*
- *ប្រាប់ឈ្មោះស្ត្រីល្បីល្បាញម្នាក់ដែលមានការអប់រំ ។*
- *ប្រាប់មូលហេតុមួយចំនួនដែលថាការអប់រំមានសារៈសំខាន់ ។*
- *តើត្រូវធ្វើអ្វីខ្លះដើម្បីកែលម្អការអប់រំកុមារា និងកុមារី?*

**ផ្នែក "ឃ"-សកម្មភាព (រយៈពេល៣០នាទី)**

គ្រូឱ្យសិស្សគិតពីមូលហេតុដែលថាការអប់រំកុមារីមានសារៈសំខាន់ ។ ឱ្យសិស្សឆ្លើយតាមរយៈការគូរគំនូរនូវសំណួរ "តើការអប់រំក្មេងស្រីជួយយើងទាំងអស់គ្នាដូចម្តេច?" ។

សូមបង្ញើរទៅក្រដាសផ្សព្វផ្សាយអំពីការប្រកួតប្រជែងគូរគំនូរដែលមានភ្ជាប់ជាមួយសម្រាប់ការណែនាំបន្ថែម (ការប្រកួតប្រជែងគូរគំនូរឈរលើមូលដ្ឋានស្ម័គ្រចិត្ត ។ វាអាចធ្វើឡើងដោយមិនបាច់ចូលរួមក្នុងការប្រកួត ខ. សិស្ស និងសាលារៀនអាចរក្សាគំនូរទុក) ។

អាចមានចម្លើយមួយចំនួនដូចខាងក្រោម:

- *កុមារីមានការអប់រំនឹងធំដឹងក្តីឡើងក្លាយជាស្ត្រីដែលមានចំណេះដឹង និងទំនងជានឹងមានសុខភាពល្អ និងមានអំណាចផ្នែកសេដ្ឋកិច្ច (រកប្រាក់ចំណូល) ហើយកូនរបស់នាងទំនងជានឹងទៅរៀន ។*
- *ស្ត្រីមានការអប់រំផ្តល់ការគាំពារផ្នែកសុខភាពល្អប្រសើរសម្រាប់ខ្លួនពួកគេផ្ទាល់ និងកូនរបស់ពួកគេ និង*

- *ការឆាប់រៀបការអាចត្រូវបានពន្យា និងការឆ្លងជម្ងឺដូចជាជម្ងឺអេដស៍អាចត្រូវបានកាត់បន្ថយ ។*

គ្រូឱ្យសិស្សស្រមៃថាតើជីវិតរបស់ក្មេងនឹងដូចម្តេចទៅ ប្រសិនបើពួកគេមិនដែលទៅរៀន?

- គ្រូឱ្យសិស្ស២-៣នាក់និយាយពីផលប៉ះពាល់នៃការដែលមិនមានការអប់រំ ។

គ្រូលើកឧទាហរណ៍អំពីផលប្រយោជន៍នៃការអប់រំមនុស្សគ្រប់រូប រួមទាំងក្មេងស្រី ។ អាចមានចម្លើយមួយចំនួនដូចខាងក្រោម:

- *មនុស្សមានការអប់រំគឺជាមនុស្សមានសុខភាពល្អ ពីព្រោះពួកគេនឹងជ្រើសរើសអ្វីៗដែលនឹងធ្វើឱ្យមានសុខភាពល្អនៅក្នុងការរស់នៅ ហើយពួកគេក៏ទទួលបានព័ត៌មានស្តីពីការរស់នៅតាមបែបសុខភាពផងដែរ ។*
- *ការអប់រំប្រយុទ្ធប្រឆាំងនឹងភាពអត់ឃ្លាន។ ស្ត្រីមានការអប់រំទំនងជានឹងមានកូនដែលមានអាហារូបបត្ថម្ភល្អ ។*
- *ការអប់រំជួយសង្គ្រោះជីវិត ។ កុមារដែលកើតជាមួយម្តាយមានការអប់រំទំនងជានឹងរស់នៅដល់អាយុ៥ឆ្នាំពីរដង ។*
- *ការអប់រំជួយលុបបំបាត់ភាពក្រីក្រ ។*

គ្រូសួរថាតើសិស្សទាំងអស់គិតថា វាយុត្តិធម៌ដែរឬទេដែលថាស្ត្រី និងកុមារទាំងអស់មិនមានឱកាសទៅរៀន ។

# ការប្រកួតប្រជែងគូរគំនូរឆ្នាំ២០១១

## "តើការអប់រំក្មេងស្រីជួយយើងទាំងអស់គ្នាដូចម្តេច?"

ដៃគូនៃកម្មវិធីផ្តួចផ្តើមការអប់រំក្មេងស្រីរបស់អង្គការសហប្រជាជាតិ (UNGEI) អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច (EAF) និង អាស៊ីខាងត្បូង (SA) មានសេចក្តីសោមនស្សសូមគោរព អញ្ជើញចូលរួមការប្រកួតប្រជែងស្តីពីការលើកកម្ពស់សមភាពយេនឌ័រក្នុងការអប់រំ ។

ការប្រកួតប្រជែងឆ្នាំនេះ សូមស្វាគមន៍បេក្ខជនដាក់ជូនគំនូរដែលនឹងបង្ហាញពីការគិតរបស់បេក្ខជនស្តីពីថា

**តើការអប់រំក្មេងស្រីជួយយើងទាំងអស់គ្នាដូចម្តេច?**

### រង្វាន់

- គំនូរជ័យលាភីចំនួន១៣ នឹងដាក់ចូលទៅក្នុងប្រតិទិនយេនឌ័រនៅក្នុងការអប់រំឆ្នាំ២០១២របស់ UNGEI (EAP និង SA) ដែលនឹងត្រូវផ្សព្វផ្សាយ យ៉ាងទូលំទូលាយទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិច ។
- បេក្ខជនដែលទទួលបានជ័យលាភីនឹងទទួលបានប័ណ្ណសរសើរជាផ្លូវការ ។
- គំនូរជ័យលាភីក៏នឹងត្រូវបង្ហោះនៅតាមគេហទំព័ររបស់អ្នករៀបចំនីមួយផងដែរ ។ ជាងនេះទៅទៀត គំនូរជ័យលាភី និងគំនូរឯទៀតនៅក្នុងការប្រកួតប្រជែងនឹងប្រើ ប្រាស់ដោយទីភ្នាក់ងារដៃគូរបស់ UNGEIនៅក្នុងការបោះពុម្ព បទបង្ហាញ គេហទំព័រ និងសម្ភារផ្សព្វផ្សាយ និងតស៊ូមតិ ។

### លក្ខណពិសេសនៃគំនូរ

គំនូរគប្បីបង្ហាញទស្សនរបស់បេក្ខជនស្តីពីថា **"តើការអប់រំរបស់ក្មេងស្រីជួយយើងទាំងអស់គ្នាដូចម្តេច?"** ។

- ត្រូវប្រគល់គំនូរទំហំអេហ្វ (A4)
- គំនូរអាចជាគំនូរពណ៌ (color) ឬសខ្មៅក៏បាន ។
- អ្នកអាចប្រើសម្ភារផ្សេងៗ (ខ្មៅដៃពណ៌ ខ្មៅដៃ និង ពណ៌ -ល-) ដែលអ្នកចូលចិត្ត ។
- គំនូរអាចពណ៌នាសកម្មភាពផ្សេងៗ ។ ឧទាហរណ៍:
  - សកម្មភាពកីឡា
  - សកម្មភាពនៅផ្ទះ
  - សកម្មភាពលេងជាមួយគ្នា
  - បរិស្ថានសាលារៀន

### សិទ្ធិចម្លង

ការដាក់ជូនគំនូរមានន័យថាបេក្ខជនបានផ្តល់ឱ្យសមាជិកទីភ្នាក់ងាររៀបចំរបស់ UNGEI (EAP និង SA) នូវសិទ្ធិប្រើប្រាស់គំនូរ ឈ្មោះ អាយុ និងឈ្មោះប្រទេសរបស់បេក្ខជន ក្នុងគោលបំណងលើកសរសើរនៅក្នុងការបោះពុម្ព បទបង្ហាញ គេហទំព័រ ឯកសារ និងសម្ភារផ្សព្វផ្សាយ ដែលទាក់ទងនឹងស្នាដៃរបស់អង្គភាពខាងលើ ដោយមិនផ្តល់ប្រាក់សំណង និងការជូនដំណឹង និងដោយមិនសុំការអនុញ្ញាត ។

### តើនរណាខ្លះមានសិទ្ធិចូលរួមក្នុងការប្រកួតប្រជែងគំនូរឆ្នាំ២០១១នេះ?

- ការប្រកួតប្រជែងនេះបើកសិទ្ធិដល់គ្រប់ជនជាតិនិង អ្នករស់នៅទាំងអស់ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ។
- បេក្ខជនត្រូវមានអាយុ១៨ឆ្នាំ ឬក្រោម១៨ឆ្នាំ ។
- កុមារា និងកុមារីត្រូវបានលើកទឹកចិត្តឱ្យចូលរួម ។

## ចំនួនគំនូរដែលត្រូវប្រគល់

បេក្ខជននីមួយៗអាចដាក់ជូនគំនូរមួយ ឬលើសពីមួយ ។

## តើត្រូវប្រគល់គំនូរដូចម្តេច?

សូមបំពេញទម្រង់ព័ត៌មានផ្ទាល់ខ្លួនដែលមានភ្ជាប់ និង សរសេរផ្នែកខាងក្រោយគំនូរនូវឈ្មោះពេញ អាយុ ភេទនិង ប្រទេស ។

ការប្រគល់គំនូរសម្តែងនូវការយល់ស្របក្នុងការបញ្ជាក់ឈ្មោះ អាយុ និងប្រទេសរបស់បេក្ខជនក្នុងការបោះពុម្ព និង គេហទំព័ររបស់ UNGEI ដោយនឹងមិនមាននូវការបោះពុម្ពព័ត៌មានអំពីអត្តសញ្ញាណលើសពីនេះទេ ។

គំនូរអាចប្រគល់ជាឯកសារបោះពុម្ព (hard copies)ក៏បាន ឬជាឯកសារអេឡិចត្រូនិក (digital mode) ក៏បាន ។

សូមបេក្ខជនផ្ញើរគំនូរតាមប្រៃសណីយទៅកាន់:

UNESCO ក្នុងក្រុងបាងកក ប្រទេសថៃ
អង្គភាពឧទ្ធរណ៍ (Appeal Unit)
920 Sukhumvit Road, Prakanong, Klongtoey
Bangkok 10110, Thailand

ឬផ្ញើរអ៊ីម៉ែលទៅកាន់:
gender.bgk@unesco.org

(ការប្រគល់គំនូរជាឯកសារអេឡិចត្រូនិកត្រូវតែជាទម្រង់ TIFF, EPS ឬ JPEG ដែលមាន resolution យ៉ាងហោចណាស់ 300 dpi) ។

## កាលបរិច្ឆេទកំណត់នៃការប្រគល់គំនូរ

**គំនូរទាំងអស់ត្រូវប្រគល់ត្រឹមថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១។**

## ការបោះឆ្នោតជ្រើសរើសគំនូរ

គំនូរដែលទទួលបានទាំងអស់នឹងឆ្លងកាត់ដំណើរការបោះឆ្នោតចំនួនពីរជុំ: **១)** ការបោះឆ្នោតជុំទីមួយធ្វើឡើងដោយដៃគូរបស់ UNGEI **២)** ការបោះឆ្នោតជុំទីពីរនឹងរៀបចំឡើងតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (online) និងបើកចំហចំពោះសាធារណជនទាំងអស់ឱ្យធ្វើការបោះឆ្នោត ។

គំនូរជ័យលាភីនឹងប្រកាសនៅខែវិច្ឆិកា ឆ្នាំ២០១១ ។

សម្រាប់ព័ត៌មានបន្ថែម សូមផ្ញើរអ៊ីម៉ែលមកកាន់យើង តាមរយៈអាស័យដ្ឋាន: gender.bgk@unesco.org ។

**ការប្រកួតប្រជែងគូរគំនូរឆ្នាំ២០១១**

**"តើការអប់រំក្មេងស្រីជួយយើងទាំងអស់គ្នាដូចម្តេច?"**

## ទម្រង់ចុះឈ្មោះ

សម្រាប់គំនូរ និងបេក្ខជននីមួយៗ សូមបង្ហាញព័ត៌មានដូចខាងក្រោមជាភាសាអង់គ្លេស:

**នាម:**

**គោត្តនាម:**

**អាយុ:**

**ភេទ:**

**ប្រទេស:**

**អាស័យដ្ឋានប្រៃសណីយ:**

**អាស័យដ្ឋានអ៊ីម៉ែល:**

ការប្រគល់គំនូរសម្តែងនូវការយល់ស្របក្នុងការបញ្ជាក់ឈ្មោះ អាយុ និងប្រទេសរបស់បេក្ខជន ហើយនឹងមិនមាននូវការបោះពុម្ពព័ត៌មានអំពីអត្តសញ្ញាណលើសពីនេះទេ ។

**ហត្ថលេខារបស់បេក្ខជន:** ............................

**ហត្ថលេខារបស់អាណាព្យាបាល/គ្រូ:** ......................